ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការអញ្ជើញឲ្យដាក់សំណើដេញថ្លៃ

ការអញ្ជើញលេខ: CDRR/KPC-CONCRETE ROAD-0308

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ
នៅថ្នាក់ក្រោមជាតិ
គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន
សមាសភាគ C

មូលនិធិលេខ: 9178-CAM

មានបំណងជ្រើសរើសអ្នកទទួលការ ដើម្បីអនុវត្តការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធដូចខាងក្រោម: ឈ្មោះកិច្ចសន្យា៖ **សាងសង់ផ្លូវបេតុងអាមេ ប្រវែង៣០០ម៉ែត្រ ទទឹងផ្លូវ ៤ម៉ែត្រ កម្រាស់០,១៥ម៉ែត្រ ស្ថិតនៅភូមិផ្សារថ្មី ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម**។

១. រាជរដ្ឋាភិបាលកម្ពុជាបានទទួលជំនួយឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ការចំណាយលើគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន ហើយមានបំណងប្រើប្រាស់មួយផ្នែកនៃជំនួយឥតសំណងនេះសម្រាប់ចំណាយលើកិច្ចសន្យា **សាងសង់ផ្លូវបេតុងអាមេ ប្រវែង ៣០០ម៉ែត្រ ទទឹងផ្លូវ ៤ម៉ែត្រ កម្រាស់០,១៥ម៉ែត្រ**(CDRR/KPC-CONCRETE ROAD-0308)។

២. តម្លៃប៉ាន់ស្មានសម្រាប់កិច្ចសន្យានេះគឺ ៣០.៦០១ ដុល្លារសហរដ្ឋអាមេរិក (សាមសិបពាន់ ប្រាំមួយរយមួយដុល្លារសហរដ្ឋអាមេរិកគត់)។

៣. កាលវិភាគសាងសង់មានរយៈពេល ០២ ខែ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើម

៤. អ្នកទទួលការមានសិទ្ធិ និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានចំណាប់អារម្មណ៍ ត្រូវបានអញ្ជើញឱ្យមកទទួលយកឯកសារដេញថ្លៃចំនួនមួយច្បាប់ដោយឥតគិតថ្លៃ នៅអាសយដ្ឋានខាងក្រោម។

៥. ដើម្បីក្លាយជាអ្នកដែលមានសិទ្ធិ អ្នកទទួលការត្រូវ ៖

ក. បានចុះបញ្ជីការស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខ. មិនបិតនៅក្រោមការហាមឃាត់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ឬធនាគារអភិវឌ្ឍន៍អាស៊ី។

៦. ដើម្បីចាត់ទុកជាអ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អ្នកទទួលការត្រូវ ៖

ក. ក្នុងរយៈពេល **៣ឆ្នាំចុងក្រោយ** ធ្លាប់បានបញ្ចប់កិច្ចសន្យាយ៉ាងតិចចំនួន២ នៃប្រភេទការងារប្រហាក់ប្រហែលគ្នាដែលកិច្ចសន្យានិមួយៗមានតម្លៃយ៉ាងតិច **៧៥%**នៃតម្លៃដាក់ដេញថ្លៃ។

ខ. រយៈពេល២ឆ្នាំចុងក្រោយអ្នកម៉ៅការត្រូវមានផលរបរសរុបប្រចាំឆ្នាំចំនួនយ៉ាងតិច១.៥ដង នៃតម្លៃដាក់ដេញថ្លៃ។

គ. អ្នកគ្រប់គ្រងសំណង់ដែលស្នើមក ត្រូវមានបទពិសោធន៍យ៉ាងតិច ៣ឆ្នាំ ក្នុងការត្រួតពិនិត្យការងារដែលមានលក្ខណៈប្រហាក់ប្រហែល និងធ្លាប់មានតួនាទីជាអ្នកគ្រប់គ្រងការងារសំណង់ ក្នុងរយៈពេលមិនតិចជាង១ឆ្នាំ។

ឯកសារដែលជាកស្តុតាងបង្ហាញអំពីលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃត្រូវដាក់ភ្ជាប់មកជាមួយសំណើដេញថ្លៃ។

៧. **សំណើដេញថ្លៃទាំងអស់ត្រូវដាក់មកអាស័យដ្ឋានខាងក្រោម នៅត្រឹម ឬមុនម៉ោង០៨:៣០នាទីព្រឹក ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០១៧** ។ សំណើដេញថ្លៃណាដែលដាក់មកយឺត នឹងត្រូវបានបដិសេធចោល។ សំណើដេញថ្លៃដែលបានទទួលនឹងត្រូវបានបើកជាសាធារណៈភ្លាមៗ ក្រោយកាលបរិច្ឆេទផុតកំណត់នៅអាសយដ្ឋានដដែល ដោយមានវត្តមានតំណាងអ្នកដេញថ្លៃទាំងអស់ ហើយអ្នកទទួលផលគម្រោងពីសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធ ដែលមានបំណងចង់ចូលរួមត្រូវបានអនុញ្ញាតឲ្យចូលរួមដោយផ្ទាល់ ។

អាសយដ្ឋានសម្រាប់ដាក់សំណើដេញថ្លៃ និងបើកសំណើដេញថ្លៃ គឺ៖

អាសយដ្ឋាន៖ សាលាស្រុកកោះសូទិន ស្ថិតក្នុងភូមិផ្សារថ្មី ឃុំពាមប្រឡោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

បន្ទប់៖ បន្ទប់ប្រជុំ នៃសាលាស្រុកកោះសូទិន ។

៨. ម្ចាស់គម្រោងនឹងផ្តល់កិច្ចសន្យាដល់អ្នកដេញថ្លៃណា ដែលត្រូវបានពិនិត្យឃើញថា សំណើដេញថ្លៃមានតម្លៃទាបជាងគេបំផុត នឹងឆ្លើយតបទាំងស្រុងទៅតាមលក្ខខណ្ឌតម្រូវនានានៃឯកសារដេញថ្លៃ ហើយអ្នកដេញថ្លៃនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចសន្យាដោយការពេញចិត្ត។

៩. សំណើដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវលិខិតប្រកាសស្តីពីការធានាសំណើដេញថ្លៃ និងការអនុវត្តន៍កិច្ចសន្យា (bid and performance securing declaration) ដូចបានរៀបរាប់ក្នុងសេចក្តីណែនាំ សម្រាប់អ្នកដេញថ្លៃ (Instructions to Bidders) ។ ចំពោះសំណើដេញថ្លៃណាដែលមិនបានភ្ជាប់មកនូវលិខិតប្រកាសស្តីពីការធានាសំណើដេញថ្លៃ និងការអនុវត្តន៍កិច្ចសន្យានេះ នឹងត្រូវ បដិសេធន៍ចោលដោយចាត់ទុកថាមិនបានឆ្លើយតបតាមលក្ខខណ្ឌតម្រូវ ។

១០. អាសយដ្ឋានដើម្បីសាកសួរព័ត៌មាន និងទទួលយកឯកសារដេញថ្លៃគឺ៖

កញ្ញា បាន ស៊ីចាន់ ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុស្រុកកោះសូទិន

អាសយដ្ឋាន៖ សាលាស្រុកកោះសូទិន ស្ថិតក្នុងភូមិផ្សារថ្មី ឃុំពាមប្រឡោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

អ៊ីម៉ែល៖ sichannban@gmail.com

លេខទូរសព្ទ៍៖ 097 – 4981 950

ម៉ោងការងារ ព្រឹក៖ ៧.០០ ដល់ ១១.៣០ , ល្ងាច៖ ២.០០ដល់៥.៣០

១១. ក្នុងករណីដែលមានការលំបាកក្នុងការទទួលឯកសារដេញថ្លៃ ភាគីទាំងឡាយដែលមានចំណាប់អារម្មណ៍អាចទាក់ទងជាលាយលក្ខណ៍អក្សរមក ៖

ឯកឧត្តម **នី គឹមសាន**, ប្រធានគម្រោង លេខាធិការ ដ្ឋាន គ.ជ.អ.ប

អាសយដ្ឋាន៖ មហាវិថីនរោត្តម ចំការមន ភ្នំពេញ

លេខទូរសព្ទ៍៖ ០១១ ៩៧០ ៥៦៥

អ៊ីម៉ែល៖ kimsanny1973@gmail.com

និងផ្ញើឯកសារដែល ទំនាក់ទំនងនោះមួយច្បាប់ផងដែរទៅលោក **យី សុខធារិទ្ធ** ប្រធាននាយកដ្ឋាន សហប្រតិបត្តិការពហុភាគី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្លូវ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, ភ្នំពេញ, កម្ពុជា លេខទូរសព្ទ័៖ **(៨៥៥) ២៣ ៧២៤ ៦៦៤** លេខទូរសព្ទ័ដៃ៖ **(៨៥៥) ១២ ៥៨៥ ៩៥៩** អ៊ីម៉ែល៖ soksothearith_yi@mef.gov.kh

១២. រាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី នឹងប្រកាសរៀងៗខ្លួនអំពីការដកសិទ្ធិទាំងស្រុងពីក្រុមហ៊ុនដោយមិនកំណត់ពេល ឬក្នុងរយៈពេលកំណត់ណាមួយ ពីការទទួលបានកិច្ចសន្យាដែលប្រើប្រាស់មូលនិធិរាជរដ្ឋាភិបាលកម្ពុជា និងធានាគារអភិវឌ្ឍន៍អាស៊ី ប្រសិនបើនៅពេលណាមួយដែលពិនិត្យឃើញថាក្រុមហ៊ុននោះជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ឬអំពើកេងបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំ ក្នុងការប្រកួតប្រជែងដើម្បីទទួលបានកិច្ចសន្យា ឬក្នុងពេលអនុវត្តកិច្ចសន្យា។

១៣. ភាគីពាក់ព័ន្ធអាចប្តឹងតវ៉ានៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការលទ្ធកម្ម។ នីតិវិធីនៃការប្តឹងតវ៉ាបានរៀបរាប់ក្នុង ប្រការ២១ នៃសេចក្តីណែនាំសម្រាប់អ្នកដេញថ្លៃ ។

យើងខ្ញុំរង់ចាំទទួលសំណើដេញថ្លៃពេញលេញ និងឆ្លើយតបតាមលក្ខខណ្ឌតម្រូវ មុនកាលបរិច្ឆេទផុតកំណត់ដែលបានបញ្ជាក់ខាងលើ និងតាមលក្ខខណ្ឌដែលបានរៀបរាប់ក្នុងឯកសារដេញថ្លៃដោយសេចក្តីរាប់អាន។

កោះសូទិន ថ្ងៃទី ...... ខែ ..... ឆ្នាំ ២០១៧

ហត្ថលេខា និងត្រា

ឈ្មោះ.....

អភិបាលស្រុកកោះសូទិន